ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Nov-2015, 15:22
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
ភាគីដាក់ឯកសារ : សហព្រះរាជអាជ្ញា
ដាក់ជូន : អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម : អង់គ្លេស
កាលបរិច្ឆេទឯកសារ : ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** ជាមួយ**ឧបសម្ព័ន្ធសម្ងាត់១**
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល: **សាធារណៈ/Public**
ឋានៈនៃចំណាត់ថ្នាក់ឯកសារ:
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

# សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា
# ស្តីពីកិច្ចដំណើរការនីតិវិធីសវនាការលើបណ្តឹងសាទុក្ខ

---

<u>ដាក់ដោយ៖</u>
**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

<u>ផ្ញើជូន៖</u>
**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវុឌ្ឍ
ចៅក្រម C.N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele Mwachande MUMBA

<u>ចម្លងជូន៖</u>
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ៖**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តី**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញា សូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ទាក់ទងនឹងទម្រង់នានាដែលនាំទៅដល់ការជំរុញទៅមុខនូវដំណើរការនីតិវិធីនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១។ សេចក្តីសន្និដ្ឋានទាំងនេះកត់សម្គាល់លើការបញ្ជាក់របស់ នួន ជា ដែលថាគាត់ចង់ពឹងផ្អែកទៅលើសារណាបណ្តឹងសាទុក្ខជាលាយល័ក្ខណ៍អក្សររបស់គាត់ និងថាគាត់បានណែនាំឲ្យសហមេធាវីការពារក្តីរបស់គាត់មិនឲ្យធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បន្តទៀត និងកត់សម្គាល់លើសេចក្តីណែនាំដែលផ្តល់ឲ្យដោយប្រធានអង្គជំនុំជម្រះតុលាការកំពូល ("អជតក") មកកាន់ផ្នែកគាំពារការការពារក្តីនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥[1]។

២. សហព្រះរាជអាជ្ញាសន្និដ្ឋានថា កិច្ចដំណើរការនីតិវិធីសវនាការគួរចាប់ផ្តើមធ្វើជាបន្តឲ្យបានឆាប់តាមដែលអាចធ្វើបាន។ អ.វ.ត.ក បានផ្តល់ឲ្យ នួន ជា នូវក្រុមមេធាវីការពារក្តីមួយប្រកបដោយធនធានដ៏ល្អ ហើយអង្គជំនុំជម្រះនេះ ក៏បានផ្តល់ឲ្យគាត់នូវគ្រប់ឱកាសដើម្បីស្តាប់សវនាការលើបញ្ហានានា នៅក្នុងបណ្តឹងសាទុក្ខនេះដែរ។ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយសហមេធាវីរបស់គាត់រួចមក នួន ជា បានសម្រេចចិត្តដោយផ្អែកបណ្តឹងសាទុក្ខរបស់គាត់ ទៅលើសារណាជាលាយល័ក្ខណ៍អក្សរដែលមាននៅក្នុងបណ្តឹងសាទុក្ខដែលក្រុមរបស់គាត់បានធ្វើ និងសុន្ទរកថាដែលគាត់បានថ្លែងនៅក្នុងសវនាការថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ នេះ។ នៅក្នុងកាលៈទេសៈទាំងនេះ ការពន្យារពេលបន្ថែមណាមួយនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការមិនអាចជាយុត្តិកម្មឡើយ។

៣. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការតែងតាំងមេធាវីប្រចាំការ មិនមែនជាដំណោះស្រាយដែលអាចអនុវត្តបានចំពោះការរាំងស្ទះនាពេលបច្ចុប្បន្នចំពោះកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនេះឡើយ។ អាស្រ័យដោយភាពស្មុគស្មាញនៃបណ្តឹងសាទុក្ខ និងកំណត់ហេតុសវនាការ មេធាវីការពារក្តីណាម្នាក់ដែលត្រូវបានតែងតាំង នឹងត្រូវការពេលវេលាជាច្រើនខែបន្ថែមទៀតដើម្បីអាចត្រៀមខ្លួនចូលរួមក្នុងបណ្តឹងសាទុក្ខបាន ដែលជាការបង្កើនដ៏សំខាន់នូវតម្លៃនៃកិច្ចដំណើរការនីតិវិធី និង ការពន្យារពេលនៃការចេញសាលដីកាស្ថាពរលើបណ្តឹងសាទុក្ខ។ ការណ៍នេះនាំឲ្យមានភាពផ្ទុយគ្នានឹងសិទ្ធិរបស់ជនជាប់ចោទទាំងពីរ ក្នុងការទទួលបានសវនាការឆាប់រហ័ស ព្រមទាំងផលប្រយោជន៍

---

[1] **F30/15** ការអនុវត្តន៍តាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការចាត់តាំងមេធាវីត្រៀមបម្រុង សម្រាប់ការពារក្តី នួន ជា, ១៩ វិច្ឆិកា ២០១៥ ("ការអនុវត្តន៍តាមសេចក្តីណែនាំ អជតក")។

របស់ជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងមូលក្នុងការទទួលបានទាន់ពេលវេលានូវសេចក្តីសម្រេចចុងក្រោយ អំពីកិច្ចដំណើរការនីតិវិធីក្នុងសំណុះរឿង០០២/០១។

៤. នួន ជា បានបញ្ជាក់យ៉ាងច្បាស់ថា គាត់ពេញចិត្តនឹងសហមេធាវីការពារក្តីចាត់តាំងបច្ចុប្បន្នរបស់គាត់ ហើយគាត់ក៏មិនស្វែងរកការផ្លាស់ប្តូរពួកគាត់។ គាត់បានបញ្ជាក់យ៉ាងច្បាស់ថា ការបដិសេធមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ គឺស្របទៅនឹងសេចក្តីណែនាំយ៉ាងច្បាស់លាស់របស់គាត់ផ្ទាល់។ ការតែងតាំងមេធាវីប្រចាំការជាការមិនចាំបាច់ដ៏ស្របច្បាប់។ ទោះជាយ៉ាងណាក្តី ខណៈដែល អជតក អាចទទួលបានប្រយោជន៍ពីពីទស្សនៈនានាអំពីមេធាវីប្រចាំការ ឬ "មេធាវីមិត្តរបស់តុលាការ"នោះ ដោយគាំទ្រដល់គោលជំហររបស់ នួន ជា នោះ ការណ៍នេះអាចនាំឱ្យមានការយល់ច្រឡំថា តុលាការនេះកំពុងតែតែងតាំងមេធាវីដែលមិនមានការត្រៀងទុកជាមុនឱ្យ នួន ជា។ តាមការពិត នួន ជា មានក្រុមអ្នកច្បាប់ដែលបានត្រៀមរៀបចំយ៉ាងពេញលេញ និងត្រូវបានផ្គត់ផ្គង់មូលនិធិគ្រប់គ្រាន់ នៅតុលាការនេះ ហើយគាត់បានសម្រេចណែនាំពួកគេមិនឱ្យបង្ហាញអំណះអំណាងនានាក្នុងនាមរូបគាត់ទៀតផង។ គាត់ពិតជាបានពិភាក្សាជាមួយនឹងមេធាវីរបស់គាត់ មុនពេលធ្វើការសម្រេចចិត្តនេះ ហើយដូច្នេះផលវិបាកណាមួយពីការសម្រេចចិត្តដែលបានជូនដំណឹងនោះ គឺជាការទទួលខុសត្រូវរបស់ នួន ជា។

## II. ប្រវត្តិនីតិវិធី

៥. នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ សហមេធាវីការពារក្តីអន្តរជាតិ នួន ជា បានបញ្ជូនសារអេឡិចត្រូនិកមួយ ទៅកាន់មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ នៃអជតក ដែលនៅក្នុងសារនេះគាត់បានថ្លែងថា កូនក្តីរបស់គាត់កំពុងតែពិចារណាដកបណ្តឹងសាទុក្ខរបស់ខ្លួន[2]។ សហមេធាវីការពារក្តីអន្តរជាតិ នួន ជា បានថ្លែងបន្ថែមថា ជាការបន្ថែម ឬតាមជម្រើសផ្សេង គាត់ និង/ឬ នួន ជា អាចជ្រើសរើសយកការមិនចូលរួមក្នុងសវនាការបណ្តឹងសាទុក្ខ។

៦. នៅវគ្គដំបូងនៃថ្ងៃទីមួយនៃសវនាការលើបណ្តឹងសាទុក្ខគឺថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ សហមេធាវីការពារក្តីអន្តរជាតិ នួន ជា បានអវត្តមានពីកិច្ចដំណើរការនីតិវិធី[3]។ សហមេធាវីការពារក្តីជាតិរបស់គាត់មានវត្តមាន។ នួន ជា បានថ្លែងសុន្ទរកថាដែលមានរយៈពេលជាង ២០នាទី ដោយគាត់

---

[2] សារអេឡិចត្រូនិក ពីសហមេធាវីការពារក្តីអន្តរជាតិ នួន ជា លោក Victor Koppe ជូនមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់នៃអង្គជំនុំជម្រះតុលាការកំពូល Volker Nerlich, ២៨ តុលា ២០១៥ **(ឧបសម្ព័ន្ធសម្ងាត់ ១)**។

[3] សេចក្តីព្រាងនៃប្រតិចារឹកសវនាការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥ ទំព័រ១ ត្រង់ 09.03.34។

បានធ្វើការកត់សំគាល់មួយចំនួន ដែលមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់គាត់ ទាក់ទងនឹងសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌។ បន្ទាប់មក គាត់បានជូនដំណឹងដល់ អជតក ថា គាត់បានណែនាំរួចហើយដល់សហមេធាវីការពារក្តីអន្តរជាតិរបស់គាត់ មិនឱ្យចូលរួមក្នុងដំណើរការនីតិវិធីនេះទេ និងថាពេលនេះគាត់ក៏បានណែនាំដូចគ្នាដល់សហមេធាវីការពារក្តីជាតិរបស់គាត់ រួមទាំងសេចក្តីណែនាំមិនឱ្យឆ្លើយតបទៅនឹងសំណួរណាមួយដែលនឹងត្រូវបានសួរដោយចៅក្រម ឬភាគីដទៃ។ នួន ជា ក៏បានថ្លែងផងដែរថា គាត់ក៏មានបំណងចាកចេញពីកិច្ចដំណើរការនីតិវិធីនេះដោយខ្លួនឯងដែរ បន្ទាប់ពីគាត់បានបញ្ចប់សេចក្តីថ្លែងរបស់គាត់[4]។ ប៉ុន្តែ នួន ជា "បានរក្សាទុកបណ្តឹងសាទុក្ខ[របស់គាត់] វិញ" ដោយអះអាងថាគាត់បានរក្សាទុក នូវអំណះអំណាងដែលបានធ្វើនៅក្នុងសារណាបណ្តឹងសាទុក្ខ[របស់គាត់]"[5]។

៧. ចាប់ពេលនោះមក សហមេធាវីការពារក្តីជាតិ នួន ជា បានបញ្ជាក់អះអាងអំពីការណែនាំរបស់កូនក្តីគាត់ថា គាត់នឹងមិនចូលរួមក្នុងសវនាការបណ្តឹងសាទុក្ខនេះទេ ហើយនឹងចាកចេញពីបន្ទប់សវនាការនៅពេលឈប់សម្រាក។ ក្នុងពេលនេះ គាត់នឹងមិនឆ្លើយតបទៅនឹងសំណួរ ឬធ្វើការអធិប្បាយណាមួយទេ[6]។ អជតក បានជម្រាបជូនសហមេធាវីការពារក្តីជាតិ នួន ជា ថាគាត់មានកាតព្វកិច្ចត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការ ថ្វីបើមានសេចក្តីណែនាំពីកូនក្តីខ្លួនដូច្នេះក៏ដោយ និងដោយពុំគិតថា តើគាត់ចង់ប្រើប្រាស់សិទ្ធិឆ្លើយតបទៅនឹងបញ្ហាណាមួយដែលបានលើកឡើងនៅក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធីនោះឡើយ[7]។ ជាការឆ្លើយតប សហមេធាវីការពារក្តីជាតិបានអះអាងថា គាត់មានកាតព្វកិច្ចធ្វើតាមការណែនាំរបស់កូនក្តីខ្លួន[8]។ អជតក ក៏បានក្រើនរំលឹកដល់សហមេធាវីការពារក្តីជាតិ នួន ជា បន្ថែមថា វាជាឱកាសចុងក្រោយរបស់គាត់ដើម្បីធ្វើការឆ្លើយតបដោយផ្ទាល់មាត់ទាក់ទងនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ក្នុងសំណុំរឿង០០២/០១[9]។

---

4 សេចក្តីព្រាងនៃប្រតិចារឹកសវនាការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥ ទំព័រ១៧ ត្រង់ 09.41.03-09.44.48។

5 សេចក្តីព្រាងនៃប្រតិចារឹកសវនាការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥ ទំព័រ១៧ ត្រង់ 09.41.03-09.44.48។

6 សេចក្តីព្រាងនៃប្រតិចារឹកសវនាការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥ ទំព័រ១៨ ត្រង់ 09.44.48-09.46.00។

7 សេចក្តីព្រាងនៃប្រតិចារឹកសវនាការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥ ទំព័រ១៨-២១ ត្រង់ 09.46.00-09.53.13, ទំព័រ២៧ ត្រង់10.06.46។

8 សេចក្តីព្រាងនៃប្រតិចារឹកសវនាការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥ ទំព័រ២០-២២ ត្រង់ 09.49.42, 09.51.43, 09.53.13។

9 សេចក្តីព្រាងនៃប្រតិចារឹកសវនាការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥ ទំព័រ៣០ ត្រង់ 10.15.49។

៨. អជតក បានសម្រេចថា នួន ជា មានកាតព្វកិច្ចចូលរួមកិច្ចដំណើរការនីតិវិធី ដោយស្ថិតនៅក្រោមការអនុញ្ញាតរបស់អង្គជំនុំជម្រះ។ បន្ទាប់ពីទទួលបានរបាយការណ៍វេជ្ជសាស្ត្រពី នួន ជា អជតក ក៏បានអនុញ្ញាតតាមសំណើរបស់គាត់ ដែលសុំទៅបន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ[10]។

៩. បន្ទាប់ពីការឈប់សម្រាក ចូលវគ្គទីពីរនៃកិច្ចដំណើរការនីតិវិធី គេពុំឃើញមានវត្តមានទាំងសហមេធាវីការពារក្តីជាតិ និងទាំងសហមេធាវីការពារក្តីអន្តរជាតិ នួន ជា ទេ[11]។ ដោយបានស្តាប់យោបល់ និងសេចក្តីសង្កេតនានារបស់ភាគី អជតក បានដកថយទៅពិចារណាពីរបៀបថាតើនឹងត្រូវដំណើរការយ៉ាងម៉េចនៅក្នុងកាលៈទេសៈដូច្នេះ។ នៅក្នុងវគ្គទីបីនៃថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥នេះដែរ អជតក បានសម្រេចផ្អាកសវនាការលើបណ្តឹងសាទុក្ខ និងបានណែនាំឲ្យអង្គភាពគាំពារការការពារក្តីតែងតាំងមេធាវីប្រចាំការសម្រាប់ នួន ជា[12]។ សហមេធាវីការពារក្តីជាតិ នួន ជា មានវត្តមាននៅវគ្គទីបីនេះ។

១០. នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ សហមេធាវីការពារក្តីជាតិ នួន ជា បានបញ្ជាក់អះអាងពីឆន្ទៈរបស់គាត់ក្នុងការគោរពតាមការបង្គាប់របស់អង្គជំនុំជម្រះ ដែលឲ្យគាត់មានវត្តមាននៅក្នុងបន្ទប់សវនាការសម្រាប់សវនាការបណ្តឹងសាទុក្ខ ប៉ុន្តែបានបញ្ជាក់បន្ថែមថា គាត់មានបំណងធ្វើតាមការណែនាំរបស់ នួន ជា ដែលមិនឲ្យគាត់ធ្វើសេចក្តីសន្និដ្ឋាន ឬការឆ្លើយតបណាមួយទៅនឹងសំណួរគ្រប់ប្រភេទទាំងអស់ដែលធ្វើឡើងដោយចៅក្រម ឬភាគីដទៃ[13]។

១១. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាបានដាក់សំណៅមុននេះមួយនៃសេចក្តីសន្និដ្ឋាននេះជាភាសាអង់គ្លេសតែប៉ុណ្ណោះ ដែលក្រឡាបញ្ជី អជតក ចាត់ទុកថាមិនគ្រប់គ្រាន់ ដោយសារតែ *ក្នុងចំណោមរឿងផ្សេងទៀត* “បញ្ហានេះត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះតុលាការកំពូលរួចហើយ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ តាមរយៈសេចក្តីសម្រេចផ្ទាល់មាត់”[14]

---

[10] សេចក្តីព្រាងនៃប្រតិចារឹកសវនាការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥ ទំព័រ២៥ ត្រង់ 10.02.14, ទំព័រ៣៦។

[11] សេចក្តីព្រាងនៃប្រតិចារឹកសវនាការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥ ទំព័រ៣២ ត្រង់ 32 at 10.50.02។

[12] សេចក្តីព្រាងនៃប្រតិចារឹកសវនាការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥ ទំព័រ៣៨។

[13] **F30/13** ការឆ្លើយតបរបស់លោក សុន អរុណ ទៅនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះតុលាការកំពូលអំពីហេតុការណ៍ដែលបានកើតឡើងនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥, ១៨ វិច្ឆិកា ២០១៥។

[14] Email from SCC Greffier to OCP Greffier, 20 November 2015.

១២. ក្រោយមកទៀតនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ប្រធាន អជតក បានចេញសេចក្តីណែនាំជាសាធារណៈទៅកាន់ DSS ដែលក្នុងនោះគាត់បានផ្តល់ការបញ្ជាក់បន្ថែមទៀតទាក់ទងនឹង ការតែងតាំងមេធាវីប្រចាំការសម្រាប់ នួន ជា។ *ក្នុងចំណោមបញ្ហាផ្សេងទៀត*លោកប្រធានបានលើកឡើងថា៖

> តួនាទីរបស់មេធាវីត្រៀមបម្រុង ពុំមែនត្រូវជំនួសមេធាវីដែលត្រូវបានជ្រើសរើសការពារក្តី នួន ជា នោះទេ។ មេធាវីបម្រុង ត្រូវទទួលខុសត្រូវចំពោះការត្រៀមរៀបចំ និងធានាលទ្ធភាពទទួលបន្ទុក ការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការ កំពូល ក្នុងករណីដែលសហមេធាវីជាតិ និងអន្តរជាតិ ការពារក្តី នួន ជា អវត្តមាននៅក្នុងបន្ទប់ សវនាការនៅពេលដែលសវនាការត្រូវបន្ត ឬអវត្តមានអំឡុងពេលនៃសវនាការទាំងមូល។ អាស្រ័យហេតុនេះ មេធាវីបម្រុង ត្រូវតែចូលរួមសវនាការបណ្តឹងសាទុក្ខទាំងអស់នៅក្នុង សំណុំរឿង០០២/០១ ត្រូវតែឯករាជពីក្រុមមេធាវីបច្ចុប្បន្នការពារក្តី នួន ជា និងពុំត្រូវពិគ្រោះ ពិភាក្សា ឬទទួលការណែនាំពី នួន ជា លើកលែងតែមានការបង្គាប់ពីអង្គជំនុំជម្រះតុលាការ កំពូល។ បន្ទាប់ពីមានសំណើសុំសមហេតុផល មេធាវីបម្រុង នឹងត្រូវបានផ្តល់ឲ្យនូវពេលវេលាគ្រប់គ្រាន់ ក្នុងការស្វែងយល់នូវសំណុំរឿងដោយខ្លួនឯងជាមួយនឹងសាលក្រមរបស់អង្គជំនុំជម្រះ សាលាដំបូងក្នុងសំណុំរឿង០០២/០១ សារណាបណ្តឹងសាទុក្ខនីមួយៗរបស់ នួន ជា និង ខៀវ សំផន សារណាតបនីមួយៗរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹង រដ្ឋប្បវេណី រួមទាំងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាផងដែរ។ មេធាវីបម្រុង ពុំត្រូវ បានប្រគល់សិទ្ធិឲ្យការពារក្តី នួន ជា រហូតទាល់តែអង្គជំនុំជម្រះនេះ បានបង្គាប់ឲ្យមេធាវីធ្វើ ដូច្នោះ។
>
> យើងពិចារណាឃើញថា តួនាទីនេះ គឺសក្តិសមសម្រាប់មេធាវីជាតិ ដែលត្រូវជ្រើសតាំងចេញពីបញ្ជីឈ្មោះមេធាវី ដោយអនុលោមតាមវិធាន ១១(២)(ឃ)(១) នៃវិធានផ្ទៃក្នុងដែលមានការយល់ដឹងនូវកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក[15]។

---

[15] **F30/15** ការអនុវត្តតាមសេចក្តីណែនាំ អជតក, ទំព័រ ៣-៤។

## III. ច្បាប់ជាធរមាន

១៣. មាត្រា ៣៥ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖

ខ. ត្រូវទទួលបានការជំនុំជម្រះដោយគ្មានការអូសបន្លាយ។

គ. ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យ និងការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ និងទទួលបាននូវជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ប្រសិនបើជនជាប់ចោទ គ្មានលទ្ធភាពជួលដោយខ្លួនឯង។

ឃ. ពិនិត្យភ័ស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភ័ស្តុតាងដោះបន្ទុកក្នុងលក្ខខណ្ឌដូចគ្នានឹងភ័ស្តុតាងដាក់បន្ទុកដែរ[16]។

១៤. វិធាន៨១ នៃវិធានផ្ទៃក្នុង[17] ចែងត្រង់ផ្នែកដែលពាក់ព័ន្ធ ថា៖

១. ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ លើកលែងតែមានបញ្ញត្តិផ្សេងចែងក្នុងវិធាននេះ។

[...]

៣. នៅពេលដែលជនជាប់ចោទបដិសេធមិនចូលរួមក្នុងនីតិវិធី ជនជាប់ចោទនឹងត្រូវនាំខ្លួនមកកាន់អង្គជំនុំជម្រះសាលាដំបូងដោយកំលាំងសាធារណៈប្រសិនបើចាំបាច់ នៅពេលនោះ ជនជាប់ចោទត្រូវតែបានជូនដំណឹងអំពីសិទ្ធិ ដែលត្រូវមានជំនួយពីមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬ សិទ្ធិទទួលបានការចាត់តាំងមេធាវីដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ ឬ សិទ្ធិការពារក្តីដោយខ្លួនឯង។

---

[16] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ១០ សីហា ២០០១, បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឲ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ២០០៤ (នស/រកម/១០០៤/០០៦)។

[17] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៩), វិសោធនកម្មនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ (“វិធាន”)។

៤. ក្រោយពេលបង្ហាញខ្លួនជាលើកដំបូង និងបានទទួលដីកាកោះដោយត្រឹមត្រូវសម្រាប់ចូលរួមក្នុងសវនាការជាបន្តបន្ទាប់ ប្រសិនបើជនជាប់ចោទនៅតែបន្តបដិសេធ ឬ ខកខានមិនបានចូលរួម ឬ ត្រូវបានបណ្តេញចេញពីកិច្ចដំណើរការនីតិវិធីដោយស្របទៅតាមវិធានផ្ទៃក្នុងនេះ កិច្ចដំណើរការនីតិវិធីអាចបន្តទៅបានដោយអវត្តមានរបស់ជនជាប់ចោទរូបនោះ។ ក្នុងករណីនេះ ជនជាប់ចោទអាចត្រូវបានការពារនៅក្នុងកិច្ចដំណើរការនីតិវិធីដោយមេធាវីរបស់ខ្លួន។ នៅពេលដែលជនជាប់ចោទបដិសេធមិនធ្វើការជ្រើសរើសមេធាវីអង្គជំនុំជម្រះសាលាដំបូង ត្រូវបង្គាប់ឲ្យមានមេធាវីការពារជនជាប់ចោទ និងស្នើឲ្យអង្គភាពគាំពារការការពារក្តី ធ្វើការចាត់តាំងមេធាវីសម្រាប់ជនជាប់ចោទពីបញ្ជីដែលមានចែងនៅក្នុងវិធាន១១។

៥. នៅពេលដែលមានមូលហេតុសុខភាព ឬ មូលហេតុធ្ងន់ធ្ងរដ៏ទៃទៀត ជនជាប់ចោទមិនអាចចូលរួមដោយផ្ទាល់ចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែ រូបកាយនិងស្មារតីសមស្របអាចចូលរួមក្នុងដំណើរការនីតិវិធីបាន អង្គជំនុំជម្រះ អាចបន្តនីតិវិធីដោយមិនមានវត្តមានរបស់ជនជាប់ចោទ ដោយមានការយល់ព្រមពីជនជាប់ចោទ ឬ នៅពេលដែលអវត្តមានរបស់ជនជាប់ចោទឈានដល់កម្រិតមួយ ដែលបណ្តាលឲ្យមានការពន្យាពេលយ៉ាងយូរហើយ នៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវ អង្គជំនុំជម្រះបង្គាប់ថា ការចូលរួមរបស់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវតែធ្វើឡើងតាមមធ្យោបាយសោតទស្សន៍សមស្រប ។ ក្នុងករណីទាំងនេះ ជនជាប់ចោទអាចត្រូវបានការពារនៅក្នុងកិច្ចដំណើរការនីតិវិធីដោយមេធាវីរបស់ខ្លួន។ នៅពេលដែលជនជាប់ចោទ បដិសេធមិនធ្វើការជ្រើសរើសមេធាវី អង្គជំនុំជម្រះសាលាដំបូង ត្រូវបង្គាប់អោយមានមេធាវីការពារជនជាប់ចោទ និងស្នើអោយអង្គភាពគាំពារការការពារក្តីធ្វើការចាត់តាំងមេធាវីសម្រាប់ជនជាប់ចោទពីបញ្ជីដែលមានចែងនៅក្នុងវិធាន ១១ នៃវិធានផ្ទៃក្នុងនេះ។

[...]

៧. នៅពេលមេធាវីរបស់ជនជាប់ចោទ មិនមានវត្តមានក្នុងអំឡុងពេលសវនាការដោយគ្មានការបញ្ជាក់អំពីមូលហេតុ អង្គជំនុំជម្រះសាលាដំបូង អាចពន្យារពេលសវនាការ ឬ បើសិនជាជនជាប់ចោទស្នើសុំជំនួយមេធាវីអាចស្នើសុំឲ្យអង្គភាពគាំទ្រការការពារក្តី ចាត់តាំងជាបណ្តោះអាសន្នជូនជនជាប់ចោទនោះនូវ មេធាវីដែលមានឈ្មោះក្នុងបញ្ជីដែលមានចែងក្នុង

វិធាន១១។ នៅពេលមេធាវីនោះមានពេលគ្រប់គ្រាន់ដើម្បីសិក្សាសំណុំរឿងរួចហើយ អង្គជំនុំជម្រះសាលាដំបូងបន្តសវនាការរបស់ខ្លួន។

១៥. វិធាន២១(៤) នៃវិធានផ្ទៃក្នុង ចែងថា៖

កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវបិទបញ្ចប់ក្នុងរយៈពេលមួយសមស្រប។

១៦. វិធាន២២(៤) នៃវិធានផ្ទៃក្នុង ចែងថា៖

នៅក្នុងការបំពេញការងាររបស់ខ្លួន មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និង បទបញ្ជារដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និង បទដ្ឋាន និង ក្រមសីលធម៌វិជ្ជាជីវៈ ដែលបានទទួលស្គាល់។ ពួកគេមានកាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធិភាព និងត្រឹមត្រូវ។

១៧. មាត្រា៧ នៃបទបញ្ជារដ្ឋបាលរបស់ផ្នែកគាំពារការការពារក្តី ចែងត្រង់ផ្នែកដែលពាក់ព័ន្ធ ថា៖

៧.១ អនុវត្តតាមដីការបស់អង្គជំនុំជម្រះវិសាមញ្ញ សហមេធាវីត្រូវការពាររឿងក្តីរហូតដល់ទីបញ្ចប់។ ប្រសិនបើខកខានអវត្តមានពីរឿងក្តី ទោះបីជាមានការអនុញ្ញាតពីអង្គជំនុំជម្រះវិសាមញ្ញក៏ដោយ តែប្រាក់ឈ្នួលមួយផ្នែក ឬទាំងអស់អាចត្រូវរឹតអូស តាមការកំណត់របស់អង្គជំនុំជម្រះវិសាមញ្ញ។

[...]

៧.៣ *ការដកខ្លួនរបស់សហមេធាវីដោយស្ម័គ្រចិត្ត:* សហមេធាវីអាចដាក់ពាក្យទៅអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីសុំដកខ្លួនចេញពីរឿងក្តី។ សហមេធាវីអាចអនុញ្ញាតឲ្យដកខ្លួនចេញពីរឿងក្តី តែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ។ សហមេធាវីត្រូវបន្តកិច្ចការពារជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទរហូតដល់មានមេធាវីថ្មីត្រូវបានចាត់តាំង ឬជ្រើសរើស[18]។

១៨. មាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ចែងថា៖

ជំនួយពីមេធាវីត្រូវតែមានដាច់ខាតនៅក្នុងករណីដូចតទៅ៖

---

[18] បទបញ្ជារដ្ឋបាលរបស់ផ្នែកគាំពារការការពារក្តី, មាត្រា៧។

១- ករណីបទឧក្រិដ្ឋ។

២- កាលណាជនជាប់ចោទជាអនីតិជន។

បើគ្មានការជ្រើសរើសដោយជនជាប់ចោទទេ មេធាវីត្រូវបានចាត់តាំងតាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[19]។

១៩. វិធាន ១០៨(៤) នៃវិធានផ្ទៃក្នុង ចែងថា អជតក "ត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនស្តីពីបណ្តឹងសាទុក្ខណាមួយប្រឆាំងនឹងសាលក្រម ក្នុងអំឡុងពេលមួយសមរម្យ" *មានន័យថា* កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ត្រូវតែបញ្ចប់ក្នុងអំឡុងពេលមួយសមរម្យ[20]។

## IV. **សេចក្តីសន្និដ្ឋាន**

### **អជតក គួរបំពេញលក្ខខណ្ឌដោយខ្លួនឯងថា នួន ជា បានលះបង់យ៉ាងច្បាស់លាស់នូវសិទ្ធមានមេធាវីចូលរួមក្នុងសវនាការបណ្តឹងសាទុក្ខ**

២០. នៅដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២/០១ នួន ជា បានបដិសេធមិនព្រមចូលរួមកិច្ចដំណើរការនីតិវិធី និងបានណែនាំមេធាវីការពារក្តីជាតិ និងអន្តរជាតិរបស់ខ្លួនមិនឲ្យបង្ហាញអំណះអំណាងនានាក្នុងនាមគាត់នោះឡើយ។

២១. ចាប់តាំងពីកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបង្ហាញទឡ្ហីករណ៍បណ្តឹងសាទុក្ខចំនួន ២២៣ សារណាបណ្តឹងសាទុក្ខចំនួន ២៧០ ទំព័រ និងចម្លើយតបចំនួន ២៤ទំព័រ តបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាលើភាពអាចអនុវត្តបាននៃទម្រង់ដែលត្រូវបានពង្រីកនៃសហឧក្រិដ្ឋកម្មរួម ("JCE3") នៅចំពោះមុខ អវតក។ បន្ថែមលើនេះទៀត គាត់បានដាក់សំណើសុំឲ្យទទួលយកភ័ស្តុតាងថ្មីបន្ថែមចំនួនប្រាំមួយ ដែលក្នុងនោះសំណើមួយចំនួនមានអំណះអំណាងស្តីពីសាលក្រម និងភ័ស្តុតាងដែលអាចអនុវត្តបានដោយផ្ទាល់ទៅនឹងទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់គាត់។ គាត់បានធ្វើសេចក្តីសន្និដ្ឋានផ្សេងៗ

---

[19] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, កញ្ញា ២០០៨, មាត្រា៣០១។

[20] **F2/4/3** សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជា សុំឲ្យទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១, ១ មេសា ២០១៥, កថាខណ្ឌ១៨។

ទៀតបង្ហាញអំពីសារៈសំខាន់នៃភស្តុតាងជាច្រើន គាត់បានសួរដេញដោលសាក្សីថ្មីៗដែលត្រូវបានកោះហៅដោយ អជតក តាមសំណើសុំរបស់គាត់ ដែលសាក្សីទាំងនោះបានផ្តល់សក្ខីកម្មក្នុងរយៈពេលបីថ្ងៃ និងបានអានការកត់សម្គាល់ដែលបានរៀបចំទុកជាមុននៅក្នុងសវនាការថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ដោយបញ្ជាក់ឡើងវិញនូវការចោទប្រកាន់នានារបស់គាត់អំពីភាពអយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី និងការរៀបរាប់របស់គាត់អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ។ នួន ជា បានបញ្ជាក់យ៉ាងច្បាស់នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ថា គាត់មិនមានបំណងបោះបង់ចោលបណ្តឹងសាទុក្ខរបស់គាត់នោះទេ ប៉ុន្តែ "យើងជ្រើសរើសផ្អែកលើអំណះអំណាងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្ញុំ"[21]។

២២. ដូច្នេះ វាច្បាស់ណាស់ថាចេតនារបស់ នួន ជា គឺលះបង់សិទ្ធិរបស់គាត់ដោយស្ម័គ្រចិត្តក្នុងការធ្វើសេចក្តីសន្និដ្ឋានបន្តទៀតដោយមានជំនួយពីមេធាវីទាក់ទងនឹងធាតុផ្សំបី ដែលមាននៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ គឺ៖ (ក) ចម្លើយតបផ្ទាល់មាត់របស់គាត់ទៅនឹងការឆ្លើយតបជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងសាទុក្ខរបស់គាត់ (ខ) សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់គាត់លើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាទាក់ទងនឹង JCE3 និង (គ) ការឆ្លើយតបផ្ទាល់មាត់របស់គាត់ទៅនឹងសំណួរច្បាប់ចំនួនប្រាំ ដែលដាក់ដោយ អជតក។ សេចក្តីសន្និដ្ឋានសរុបរបស់ នួន ជា លើរាល់ធាតុផ្សំទាំងបីនេះត្រូវបានគ្រោងដោយ អជតក ថាត្រូវប្រើរយៈពេលប្រហែល ១៦០ នាទី នៃពេលវេលាសវនាការ[22]។

២៣. នៅក្នុងរឿងក្តី *Nahimana* នៃតុលាការ ICTR ការសួរដេញដោលសាក្សីបួននាក់របស់រដ្ឋអាជ្ញាបានបន្តដោយមិនមានមេធាវីរបស់ជនជាប់ចោទ Barayagwiza ដែលបានណែនាំពួកគេមិនឲ្យចូលរួម[23]។ នៅក្នុងកិច្ចពិភាក្សាមួយទាក់ទងនឹងអានុភាពនៃការធ្វើពហិការទាំងស្រុងរបស់ជនជាប់ចោទ Barayagwiza ក្នុងកិច្ចដំណើរការនីតិវិធី[24] អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR

---

[21] សេចក្តីព្រៀងនៃប្រតិចារឹកសវការបណ្តឹងសាទុក្ខ, ១៧ វិច្ឆិកា ២០១៥, ទំព័រ ១៧។

[22] **F30/4.1** ឧបសម្ព័ន្ធ ក - កាលវិភាគស្ថាពរសម្រាប់សវនាការ, ៥ វិច្ឆិកា ២០១៥។

[23] *រដ្ឋអាជ្ញា ទល់នឹង Nahimana និងគូកន*, ICTR-99-52-T, សាលក្រម និងការកាត់ទោស (អង្គជំនុំជម្រះសាលាដំបូង I), ៣ ធ្នូ ២០០៣, កថាខណ្ឌ៨៣។

[24] អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកត់សម្គាល់ថា៖ "ចាប់ពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០០ ជាថ្ងៃដំបូងនៃសវនាការរហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៣ ថ្ងៃចុងក្រោយនៃសវនាការ ម្ចាស់បណ្តឹងសាទុក្ខ Barayagwiza ដែលបានជាប់ឃុំនៅក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះ បានកខខានមិនបានបង្ហាញខ្លួនក្នុងសវនាការ"។ *Nahimana និងគូកន.*

បានបដិសេធអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងគួរបានកោះហៅសាក្សីនានាឡើងវិញ ដែលសាក្សីទាំងនោះមិនត្រូវបានសួរដេញដោលដោយមេធាវីការពារក្ដីជនជាប់ចោទ ដោយមូលហេតុការធ្វើពហិការរបស់គាត់។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា "ឥរិយាបទរបស់ម្ចាស់បណ្ដឹងសាទុក្ខខាងលើនេះត្រូវរាប់បញ្ចូលថាជាការលះបង់សិទ្ធិក្នុងការសួរដេញដោល ឬបានសួរដេញដោលសាក្សីនានា ដែលត្រូវបានស្ដាប់សក្ខីកម្មនៅពេលនោះ"[25]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏បានកត់សម្គាល់ផងដែរថា តុលាការសិទ្ធិមនុស្សអឺរ៉ុប ("តុលាការអឺរ៉ុប") បានទទួលស្គាល់ថា ជនជាប់ចោទអាចលះបង់សិទ្ធិរបស់ខ្លួនដើម្បីសួរដេញដោលសាក្សី[26]។

២៤. អជតក គួរធ្វើការសាកសួរបន្ថែមទៀត ដើម្បីបញ្ជាក់បន្ថែមទៀតថា នួន ជា យល់យ៉ាងច្បាស់អំពីផលវិបាក នៃការសម្រេចចិត្តរបស់គាត់ក្នុងការណែនាំមេធាវីរបស់គាត់មិនឲ្យចូលរួមក្នុងសវនាការបណ្ដឹងសាទុក្ខ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("តុលាការ SCSL") បានបញ្ជាក់អំពីសារៈសំខាន់ក្នុងការធានាឲ្យបានថា ការលះបង់សិទ្ធិដោយជនជាប់ចោទគឺជាការដឹងឮ និងត្រូវបានជូនដំណឹង និងជាការលះបង់ដោយ*ជនជាប់ចោទ* មិនមែនមេធាវីរបស់គាត់នោះទេ[27]។

---

*ទល់នឹង រដ្ឋអាជ្ញា,* ICTY-99-52-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍), ២៨ វិច្ឆិកា ២០០៧ ("សាលដីកា *Nahimana*"), កថាខណ្ឌ៩៥។

25 សាលដីកា *Nahimana*, កថាខណ្ឌ ១២៥។

26 សាលដីកា *Nahimana* កថាខណ្ឌ ១២៥ ជើងទំព័រ ២៩២ ដោយយោងសំអាង *Vaturi ទល់នឹង បារាំង*, លេខ. 75699/01, ECHR (ផ្នែកទីមួយ), សាលក្រម ថ្ងៃទី១៣ មេសា ២០០៦, កថាខណ្ឌ ៥៣, និង *Craxi ទល់នឹង អ៊ីតាលី,* លេខ. 34896/97, ECHR (ផ្នែកទីមួយ), សាលក្រម ថ្ងៃទី៥ ធ្នូ ២០០២, កថាខណ្ឌ៩០-៩១។

27 នៅក្នុងរឿងក្ដី Taylor មេធាវីការពារក្ដីមិនបានដាក់សារណាចុងក្រោយតាមកាលបរិច្ឆេទកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនោះទេ តាមការណែនាំរបស់ Taylor។ សារណាចុងក្រោយត្រូវបានដាក់ក្នុងរយៈពេល២០ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទកំណត់ ដែលមានរយៈពេលពីរបីថ្ងៃមុនពេលអំណះអំណាងផ្ទាល់មាត់ដែលត្រូវបានគ្រោងទុក។ សារណាចុងក្រោយត្រូវបានបដិសេធដោយចៅក្រមភាគច្រើននៃអង្គជំនុំជម្រះសាលាដំបូង។ នៅដំណាក់កាលអំណះអំណាងផ្ទាល់មាត់ មេធាវីការពារក្ដីបាននិយាយថា៖ "... យើងមិនមានអារម្មណ៍ថាវាអាចសមរម្យចំពោះយើងដើម្បីចូលរួមនៅក្នុងការធ្វើបទបង្ហាញផ្ទាល់មាត់នោះទេ នៅពេលដែលភាគច្រើននៃអ្នកទាំងអស់គ្នាបានបដិសេធមិនទទួលយកសារណាជាលាយលក្ខណ៍អក្សររបស់យើង។ ហើយយើងមានការណែនាំរបស់លោក Talyor ក្នុងន័យនេះ។ យើងយល់ថា វាគឺជាភារៈកិច្ចវិជ្ជាជីវៈរបស់យើងដើម្បីដកមកវិញនូវសេចក្ដីសម្រេចកំពុងរង់ចាំលើញត្តិរបស់ពួកយើងប្ដឹងសាទុក្ខទៅនឹងសេចក្ដីសម្រេចកាលពីម្សិលម៉ិញ ដែលនឹងត្រូវដាក់នៅថ្ងៃនេះ"។ (*សូមមើល រដ្ឋអាជ្ញា ទល់នឹង Taylor*, SCSL-03-01-T, ប្រតិចារឹកទឡ្ហីករណ៍ផ្ទាល់មាត់, ៨ កុម្ភៈ ២០១១, ទំព័រ ៤៩១៣៨)។ បញ្ហានេះក្រោយមកបានទៅដល់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការ SCSL ដែលបាន

២៥. តុលាការអឺរ៉ុប បាននិយាយថា “ពាក្យពេចន៍ និងស្មារតីនៃមាត្រា ៦ នៃ [អនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (“អនុសញ្ញា”)]” មិនបានរារាំងបុគ្គលពីការលះបង់ឥស្សរៈចិត្តផ្ទាល់ខ្លួនរបស់គាត់ ដោយឱទ្យារិក ឬដោយស្ងៀមស្ងាត់នោះឡើយ ដែលនេះជាសិទ្ធិធានាដល់ការជំនុំជម្រះប្រកប ដោយយុត្តិធម៌[28]។ ការលះបង់សិទ្ធិដែលធានាដោយអនុសញ្ញានោះ ដែលអាចត្រូវបានអនុញ្ញាតត្រូវតែ

---

និយាយថា “សិទ្ធិទទួលសវនាការនៅចុងបញ្ចប់នៃការជំនុំជម្រះគឺជាសិទ្ធិរបស់ជនជាប់ចោទ មិនមែនមេធាវីរបស់គាត់នោះទេ។ ការអនុវត្តន៍សិទ្ធនោះតាមវិធាន ៨៦ គឺជាឆន្ទានុសិទ្ធិ ប៉ុន្តែវាគឺជាឆន្ទានុសិទ្ធិរបស់ជនជាប់ចោទដែលត្រូវអនុវត្ត មិនមែនមេធាវីការពារក្ដីរបស់គាត់នោះទេ”។ *សូមមើល រដ្ឋអាជ្ញា ទល់នឹង Taylor,* SCSL-03-01-T-1223, សេចក្ដីសម្រេចលើការជូនដំណឹងបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី និងសេចក្ដីសន្និដ្ឋានទាក់ទងនឹងសេចក្ដីសម្រេចលើការដាក់សារណាជំនុំជម្រះចុងក្រោយយឺតដោយមេធាវីការពារក្ដី, កថាខណ្ឌ ៥៩។ វាបន្តនៅកថាខណ្ឌ ៥៧ ថា៖ “ដូចក្នុងករណីនេះ នៅពេលដែលការរឹបអូសមានន័យថាជាការលះបង់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទនោះ តុលាការមានកាតព្វកិច្ចមួយត្រូវឱ្យប្រាកដថា ជនជាប់ចោទយល់ថាផលវិបាកនៃអំពើនានា និងការតំណាងរបស់មេធាវីការពារក្ដី អាចត្រូវបានបកស្រាយថាជាការលះបង់សិទ្ធិរបស់ជនជាប់ចោទក្នុងការមានសវនាការ និងដើម្បីការពារខ្លួននៅចុងបញ្ចប់នៃការជំនុំជម្រះ”។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បាននិយាយថា យោងទៅលើកាលៈទេសៈនានាទាំងនេះ វាមិនសមហេតុផលទេចំពោះអង្គជំនុំជម្រះសាលាដំបូងដើម្បីសន្និដ្ឋានពីការនៅស្ងៀមរបស់ជនជាប់ចោទ ដែលគាត់បានយល់ព្រម និងបានយល់ថាដោយការធ្វើដូច្នេះ គាត់អាចនឹងកំពុងតែលះបង់សិទ្ធិជាមូលដ្ឋាន។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានថ្លែងនៅត្រង់កថាខណ្ឌ ៦៤-៦៦ ថា៖ “អង្គជំនុំជម្រះនេះគួរតែបានកំណត់ថាតើ ជនជាប់ចោទបានយល់ដឹងថាគាត់បានកំពុងតែលះបង់សិទ្ធិក្នុងការបង្ហាញនូវអំណះអំណាងបិទការពិភាក្សាដេញដោយដោយផ្ទាល់មាត់ និងឬជាលាយលក្ខណ៍អក្សរ ហើយការណ៍ដែលបានធ្វើដូច្នេះ ក្នុងវិធីជាច្រើន ដោយរួមទាំងគ្រាន់តែការប្រាស្រ័យទាក់ទង ដែលមិនតាមវិធីណាមួយរំលោភបុព្វសិទ្ធិមេធាវី-កូនក្ដីនោះ”។ អង្គជំនុំជម្រះសាលាដំបូងមិនបានបង្ហាញថា មានការលះបង់សិទ្ធិដោយដឹងឮ ដ៏ឈ្លាសវៃ និងដោយស្ម័គ្រចិត្ត ដោយជនជាប់ចោទនោះទេ។ អង្គហេតុដែលអវត្តមាន ល្មមគ្រប់គ្រាន់ដើម្បីកំណត់ការលះបង់សិទ្ធិ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ជនជាប់ចោទបានលះបង់សិទ្ធិរបស់ខ្លួន និងនៅក្នុងការបន្តនិតិវិធីហាក់ដូចជាគាត់បានលះបង់សិទ្ធិ។ “[…] ប្រសិនបើមិនកែតម្រូវទេ អាចនាំឱ្យមានភាពអយុត្តិធម៌។ ដើម្បីសម្រេចផ្សេងពីនេះ នឹងនាំឱ្យខាតប្រយោជន៍ដល់ជនជាប់ចោទដែលមិនទទួលបានការជូនដំណឹង ចំពោះសកម្មភាពរបស់មេធាវីការពារក្ដីរបស់គាត់ ដែលអាចនឹងមិនយុត្តិធម៌ ជាពិសេសនោះ ដោយសារតែមានវិធីផ្សេងៗទៀត ដែលអង្គជំនុំជម្រះសាលាដំបូងអាចដាក់ ទណ្ឌកម្មមេធាវីការពារក្ដីដោយមិនឱ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ”។ ដោយគ្មានការលះបង់សិទ្ធិច្បាស់លាស់ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកសារណាចុងក្រោយរបស់មេធាវីការពារក្ដី និងកំណត់កាលបរិច្ឆេទបើកសវនាការលើអំណះអំណាងរបស់មេធាវីការពារក្ដី។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសន្និដ្ឋានបញ្ចប់នៅក្នុងកថាខណ្ឌ៦៧ថា៖ *“ប្រសិនបើមេធាវីការពារក្ដីមានបំណងតាមរយៈពាក្យពេចន៍ ឬសកម្មភាពដើម្បីលះបង់សិទ្ធិរបស់ជនជាប់ចោទចំពោះអំណះអំណាងផ្ទាល់មាត់នោះ អង្គជំនុំជម្រះសាលាដំបូងត្រូវបានណែនាំឱ្យធានាឱ្យបានថា ជនជាប់ចោទខ្លួនគាត់ផ្ទាល់កំពុងតែលះបង់សិទ្ធិរបស់ខ្លួនដោយស្ម័គ្រចិត្ត ដោយឈ្លាសវៃ និងដោយដឹងឮ”។ (គូសបញ្ជាក់បន្ថែម)។*

[28] *Hermi ទល់នឹង អ៊ីតាលី* លេខ. 18114/02, សាលក្រម, ១៨ តុលា ២០០៦, កថាខណ្ឌ៧៣។

ធ្វើឡើងក្នុងលក្ខណៈច្បាស់លាស់ក្នុងស្ថានភាព ដែលមិនអាចចៀសវាងបាននិងមិនត្រូវផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈសំខាន់ៗណាមួយឡើយ[29]។ តុលាការអឺរ៉ុបក៏បានចង្អុលបង្ហាញផងដែរថា "មុនពេលដែលជនជាប់ចោទអាចត្រូវបានចាត់ទុកថាតាមរយៈទង្វើរបស់គាត់បានលះបង់ដោយប្រយោល នូវសិទ្ធិដ៏សំខាន់មួយតាមមាត្រា ៦ នៃអនុសញ្ញា ចាំបាច់ត្រូវបង្ហាញថា គាត់អាចប្រមើលមើលជាមុនយ៉ាងសមហេតុផលពីអ្វីដែលជាផលវិបាកចេញពីទង្វើរបស់គាត់នោះ"[30]។

២៦. ហេតុដូច្នេះ អជតក គួរតែសួរសំណួរណាក៏ដោយដែលខ្លួនយល់ថាសមរម្យ ទៅកាន់ នួន ជា រហូតទាល់តែអង្គជំនុំជម្រះបំពេញលក្ខខណ្ឌបានថា ទង្វើរបស់ នួន ជា សមមាត្រទៅនឹងការលះបង់ដែលត្រូវបានជូនដំណឹងពេញលេញ។ អង្គជំនុំជម្រះអាចពិចារណារំលឹក នួន ជា ថាគាត់នឹងត្រូវទទួលនូវផលវិបាកនានា នៃការសម្រេចចិត្តរបស់គាត់ក្នុងការមិនផ្តល់ជូននូវអំណះអំណាងបន្ថែមទៀតទាក់ទងនឹងបណ្តឹងសាទុក្ខរបស់គាត់នោះ ឬទាក់ទងនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ ជាពិសេសនោះ អជតក គួរតែបញ្ជាក់ថា នួន ជា យល់ច្បាស់ថា ខណៈដែលសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរទាំងអស់ ត្រូវបានបង្ហាញតាងនាមឲ្យរូបគាត់នឹងត្រូវបានទទួលយកដោយ អជតក នោះ ការណែនាំរបស់គាត់មិនឲ្យមេធាវីចូលរួមក្នុងសវនាការនឹងមានន័យថាមេធាវីនឹងមិនបង្ហាញអំណះអំណាងនានាតាងនាមឲ្យរូបគាត់ ក្នុងអំឡុងពេលសវនាការបណ្តឹងសាទុក្ខនោះទេ ឬជំទាស់ទៅនឹងអំណះអំណាងរបស់ភាគីនានាដទៃទៀត ឬឆ្លើយតបទៅនឹងសំណួរណាមួយពីចៅក្រមនៃ អជតក នោះឡើយ។ នួន ជា គួរត្រូវបានជូនដំណឹងទៀតថា គាត់មានសិទ្ធិណែនាំមេធាវីរបស់គាត់ឲ្យបន្តការតំណាងឡើងវិញនៅពេលណាមួយ ប៉ុន្តែថាកិច្ចដំណើរការនីតិវិធីដែលបានធ្វើក្នុងអំឡុងរយៈពេលគ្មានការចូលរួមរបស់មេធាវីគាត់នោះ នឹងមិនត្រូវបានធ្វើឡើងវិញនោះឡើយ។

២៧. សហព្រះរាជអាជ្ញាយល់ឃើញថា នៅពេលដែល អជតក ត្រូវបានបំពេញគ្រប់លក្ខខណ្ឌថាការលះបង់សិទ្ធិរបស់ នួន ជា គឺជាការស្ម័គ្រចិត្ត និងត្រូវបានជូដំណឹង ជម្រើសរបស់គាត់មិនឆ្លើយតបទៅនឹងអំណះអំណាងដោយផ្ទាល់មាត់នោះ គឺមិនខុសពីការសម្រេចចិត្តមួយមិនឆ្លើយតបទៅនឹងអំណះអំណាងដែលមាននៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនោះឡើយ។

---

[29] *Hermi ទល់នឹង អ៊ីតាលី* លេខ. 18114/02, សាលក្រម, ១៨ តុលា ២០០៦,§ ៧៣។ *Sejdovic ទល់នឹង អ៊ីតាលី* លេខ. 56581/00, សាលក្រម, ១ មីនា ២០០៦, § ៨៦។

[30] *Hermi ទល់នឹង អ៊ីតាលី* លេខ. 18114/02, សាលក្រម, ១៨ តុលា ២០០៦,§ ៧៤។ *Sejdovic ទល់នឹង អ៊ីតាលី* លេខ. 56581/00, សាលក្រម, ១ មីនា ២០០៦, § ៨៧។

គាត់ត្រូវបានបន្តការពារសិទ្ធិដោយមេធាវីតាមការជ្រើសរើសរបស់គាត់ និងធ្វើការការពារក្តីខ្លួនឯងក្នុងវិធីមួយ ដែលតាមរយៈការណែនាំរបស់មេធាវីការពារក្តីរបស់គាត់ ដែលគាត់ជឿជាក់ថាមានប្រសិទ្ធភាពបំផុត សម្រាប់លទ្ធផលចុងក្រោយដែលគាត់ស្វែងរក។

**អជតក ត្រូវតែធានាដល់ការប្រើប្រាស់សមរម្យនៃធនធានដ៏មានកម្រិតរបស់តុលាការ**

២៨. នៅពេលដោះស្រាយជាមួយនឹងបញ្ហាទាក់ទងនឹងការតំណាងរបស់មេធាវី អជតក អាច និងគួរតែពិចារណាអំពីភាពពិតជាក់ស្តែងដែលតុលាការដំណើរការទៅ ក្នុងបរិបទ នៃធនធានដ៏មានកម្រិត។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICRT ក្នុងរឿងក្តី *Akayesu* នៅពេលពិចារណាអំពីសិទ្ធិរបស់ជនជាប់ចោទក្រីក្រម្នាក់ក្នុងការមានមេធាវីតាមការជ្រើសរើសរបស់ខ្លួននោះ បាននិយាយថា ការណ៍នេះ "លើកឡើងពីបញ្ហានៃការថ្លឹងថ្លែងអំពីលក្ខខណ្ឌតម្រូវចំនួនពីរ៖ មួយនោះគឺធ្វើឲ្យជនជាប់ចោទទទួលបាននូវមេធាវីការការពារក្តីដ៏មានប្រសិទ្ធភាពដូចអាចធ្វើទៅបាន ដើម្បីធានាដល់ការជំនុំជម្រះដោយយុត្តិធម៌ និងមួយវិញទៀតនោះគឺ ការប្រើប្រាស់ធនធានរបស់តុលាការឲ្យបានសមរម្យ"[31]។

២៩. អវតក បានចំណាយថវិការាប់លានដុល្លារ ដើម្បីធានាថា នួន ជា និង ខៀវ សំផន ម្នាក់ៗទទួលបានក្រុមមេធាវីការពារក្តីប្រកបដោយគុណវុឌ្ឍិតាមទូទាំងកិច្ចដំណើរការនីតិវិធីនានា ដែលបានចាប់ផ្តើមពីការចាប់ខ្លួនពួកគាត់ក្នុងឆ្នាំ ២០០៧។ តុលាការបានផ្តល់មូលនិធិក្រុមទាំងនោះដើម្បីផ្តល់លទ្ធភាពឲ្យពួកគាត់ធ្វើការស្រាវជ្រាវផ្នែកច្បាប់លើវិស័យស្មុគស្មាញនានានៃច្បាប់សារធាតុ និងច្បាប់នីតិវិធីជាតិ និងអន្តរជាតិ ក៏ដូចជា ដើម្បីឲ្យពួគេយល់ដឹងអំពីការជំនុំជម្រះទ្រង់ទ្រាយធំ និងកំណត់ត្រាបណ្តឹងសាទុក្ខក្នុងសំណុំរឿងនេះ ដោយរួមបញ្ចូលទាំងបរិមាណដ៏ច្រើននៃភស្តុតាងជាឯកសារ និងជាសក្ខីកម្ម ដើម្បីបង្ហាញអំណះអំណាងនានាតាងនាមឲ្យកូនក្តីរបស់ពួកគេ។ នៅក្នុងដំណាក់កាលជិតចុងក្រោយនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០១ នេះ តុលាការមិនគួរត្រូវបានរំពឹងទុកថានឹងផ្តល់មូលនិធិសម្រាប់មេធាវីប្រចាំការសម្រាប់ នួន ជា នោះទេ នៅពេលដែលក្រុមមេធាវីការពារក្តីមួយក្រុមធំមានរួចទៅហើយនោះ ដែលក្រុមនោះស្គាល់បានយ៉ាងល្អទៅនឹងឯកសារ និងបញ្ហានានាលើបណ្តឹងសាទុក្ខ និងដែលត្រូវបានផ្តល់មូលនិធិដោយតុលាការអស់រយៈពេលជាច្រើនឆ្នាំមកហើយនោះ។

---

31 *រដ្ឋអាជ្ញា ទល់នឹង Akayesu*, ICTR-96-4-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍), ១ មិថុនា ២០០១, កថាខណ្ឌ៦២។

## ការតែងតាំងមេធាវីប្រចាំការនឹងជះឥទ្ធិពលអវិជ្ជមានដល់ទាំងសិទ្ធិរបស់ជនជាប់ចោទ និងទាំងជនរងគ្រោះ ចំពោះការបញ្ចប់កិច្ចដំណើរការនីតិវិធីទាំងនេះដោយគ្មានការពន្យារពេលមិនសមស្រប

៣០. មេធាវីណាមួយដែលត្រូវបានតែងតាំងឲ្យតំណាងផលប្រយោជន៍របស់ នួន ជា នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ ទំនងជានឹងស្នើសុំការពន្យារពេលដ៏សំខាន់ណាមួយនៅក្នុងបណ្ដឹងសាទុក្ខផ្ទាល់មាត់នេះ ដើម្បីឲ្យរូបគាត់សុំទៅនឹងសំណុំរឿង និងសម្ភារៈដែលបានកំណត់ដោយប្រធាន អជតក ក្នុងសនុស្សរណៈចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ដោយចៀសមិនផុតនោះនឹងនាំឲ្យមានការពន្យារពេលបន្ថែមទៀតក្នុងការចេញសាលដីកាចុងក្រោយលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿងនេះ។

៣១. ផលប៉ះពាល់អវិជ្ជមាននៃការសម្រេចចិត្តរបស់ជនជាប់ចោទ លើសិទ្ធិផ្ទាល់ខ្លួនរបស់ជនជាប់ចោទចំពោះការជំនុំជម្រះដ៏ឆាប់រហ័ស គឺជាកត្តាពាក់ព័ន្ធដែលត្រូវពិចារណាក្នុងករណីនានាទាក់ទងនឹងការផ្ដល់ជូនមេធាវីការពារក្ដី[32]។ ដូចដែល អជតក បានកត់សម្គាល់ខ្លួនឯងផ្ទាល់ថា៖ "ដោយដឹងថាអាយុកាន់តែចាស់ និងសុខភាពរបស់ជនជាប់ចោទកាន់តែធ្លាក់ចុះ ដ៏ដូចជា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ដែលមានសេសសល់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចនេះជាការតម្រូវ ថា អ.វ.ត.ក ដំណើរការជារៀងរាល់ថ្ងៃដែលខ្លួនអាចធ្វើទៅបាន ដើម្បីធានាបាននូវការសម្រេចជាស្ថាពរលើបទចោទដែលសេសសល់ឲ្យបានឆាប់ដែលអាចធ្វើទៅបាន"[33]។

## វិធាន ៨១(៤), ៨១(៥), និង ៨១(៧) នៃវិធានផ្ទៃក្នុងមិនតម្រូវឲ្យ អជតក ផ្អាកកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខដើម្បីតែងតាំងមេធាវីប្រចាំការនោះទេ

---

[32] នៅតុលាការ ICTY, អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី *Blagojević និង Jokić* បាននិយាយថា៖ "ទិដ្ឋភាពមួយនៃសិទ្ធិចំពោះការជំនុំជ្រះដោយយុត្តិធម៌ គឺសិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័យ។ ភ្លាមៗមុនពេល ឬនៅពេលណាមួយបន្ទាប់ពីការចាប់ផ្ដើមកិច្ចដំណើរការសវនាការ លើកលែងតែសំណើក្នុងករណីពិសេសបំផុតតែប៉ុណ្ណោះសម្រាប់ការដកមេធាវីចេញ នឹងត្រូវបានធ្វើ ដោយសារតែការជំនួសមេធាវីណាមួយ នឹងមានអនុភាពលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះយ៉ាងឆាប់រហ័ស"។ សូមអាន *រដ្ឋអាជ្ញា តល់នឹង* *Blagojević និង Jokić*, IT-02-60-T, សេចក្ដីសម្រេចលើមេធាវីឯករាជសម្រាប់ ញត្តិរបស់ Vidoje Blagojević សុំណែនាំក្រឡាបញ្ជីឲ្យតែងតាំងមេធាវីនាំមុខ និងសហមេធាវី, ៣ កក្កដា ២០០៣, កថាខណ្ឌ ១១៩។

[33] **E163/5/1/13** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ៨ កុម្ភៈ ២០១៣, កថាខណ្ឌ៥១។

៣២. វិធាន៨១(៤) នៃវិធានផ្ទៃក្នុងយោងទៅលើកាលទេសៈមួយដែលជនជាប់ចោទបន្តបដិសេធ ឬខកខានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនានា ឬត្រូវបានបណ្តេញចេញពីកិច្ចដំណើរការទាំងនោះ។ វិធាន ៨១(៥) នៃវិធានផ្ទៃក្នុងយោងទៅលើសេណារីយោដែលជនជាប់ចោទ ដោយសារមូលហេតុវេជ្ជសាស្ត្រ កំពុងតាមដានកិច្ចដំណើរការនីតិវិធីនានាតាមរយៈប្រព័ន្ធសោទស្សន៍។ ក្នុងកាលៈទេសៈទាំងពីរនេះ ជនជាប់ចោទអាចត្រូវបានការពារក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីនានាដោយមេធាវីរបស់គាត់។ វិធានទាំងពីរក៏ចែងផងដែរថា៖ "នៅពេលដែលជនជាប់ចោទបដិសេធមិនធ្វើការជ្រើសរើសមេធាវី អង្គជំនុំជម្រះសាលាដំបូងត្រូវបង្គាប់ឱ្យមានមេធាវីការពារជនជាប់ចោទ និងស្នើឱ្យអង្គភាពគាំពារការការពារក្តី ធ្វើការចាត់តាំងមេធាវីសម្រាប់ជនជាប់ចោទ"។

៣៣. បទប្បញ្ញត្តិទាំងពីរនេះមិនត្រូវបានយកមកអនុវត្តនៅទីនេះទេ។ នួន ជា មិនបានបដិសេធការជ្រើសរើសមេធាវីនោះទេ។ ដូចនៅក្នុងរឿងក្តី *Barayagwiza* ដែរ នួន ជា មានមេធាវីដែលគាត់ជ្រើសរើស និងមិនតវ៉ាអំពីការតំណាងរបស់ពួកគេនោះទេ។ ចៅក្រម Gunawardana បានព្រមព្រៀងនៅក្នុងរឿងក្តី *Barayagwiza* បានហៅការណែនាំរបស់ Barayagwiza ចំពោះមេធាវីរបស់គាត់មិនឱ្យចូលរួមថាជា "ទម្រង់មួយនៃការតវ៉ា" និងបានកត់សម្គាល់ថា "រូបគាត់មិនមែនមិនពេញចិត្តនឹងការប្រព្រឹត្ត ឬសមត្ថភាពរបស់មេធាវីគាត់នោះទេ ហើយតាមពិតនោះគាត់មានទំនុកចិត្តពេញលេញលើពួកគេ"[34]។ ការណ៍នេះត្រូវអនុវត្តដូចគ្នានៅទីនេះ។ កំណត់សម្គាល់ផ្ទាល់មាត់របស់ នួន ជា នាថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ បញ្ជាក់យ៉ាងច្បាស់ថា គាត់មិនមែនមិនពេញចិត្តនឹងមេធាវីរបស់គាត់នោះទេ។ គាត់មិនចង់ប្តូរមេធាវីនោះទេ គាត់មិនចង់ឱ្យមេធាវីណាម្នាក់បង្ហាញអំណះអំណាងតាងនាមឱ្យគាត់នៅក្នុងសវនាការបណ្តឹងសាទុក្ខនោះទេ ក្នុងគោលបំណងមួយធ្វើអធម្មានរូបកម្មកិច្ចដំណើរការនីតិវិធីទាំងនោះ។ អជតក មិនបានអនុញ្ញាតឱ្យទាំងមេធាវីជាតិ និងមេធាវីអន្តរជាតិរបស់គាត់ដកខ្លួនស្របតាមវិធាន ២២(៤) និងមាត្រា ៧ នៃបទបញ្ជារដ្ឋបាលរបស់ផ្នែកគាំពារការការពារក្តី[35]។ មិនមានលក្ខខណ្ឌតម្រូវសម្រាប់ អជតក

---

[34] *រដ្ឋអាជ្ញា ទល់នឹង* *Barayagwiza*, ICTR-97-19-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីសុំដកខ្លួន, ២ វិច្ឆិកា ២០០០ យោបល់ស្រប និងយោបល់ដោយឡែករបស់ចៅក្រម Gunawardana។

[35] ការងាររបស់មេធាវីត្រូវការពារផលប្រយោជន៍កូនក្តីរបស់ខ្លួនយ៉ាងស្វាហាប់ស្ថិតក្នុងកាតព្វកិច្ចនៃវិធានរបស់តុលាការ។ មិនមានវិធានស្តីពីនីតិវិធី ឬក្រមសីលធម៌ណាដែលអនុញ្ញាតឱ្យមេធាវីគ្រាន់តែមិនគោរពតាមបញ្ជារបស់តុលាការតាមការណែនាំរបស់កូនក្តីខ្លួននោះទេ។ មិនមានតុលាការព្រហ្មទណ្ឌណាអាចបំពេញមុខងារយ៉ាងមានប្រសិទ្ធភាពនោះទេ ប្រសិនបើវាអាស្រ័យលើជនជាប់ចោទក្នុងការសម្រេចថាតើបញ្ជារបស់តុលាការមួយណាដែលមេធាវីរបស់ពួកគេនឹងគោរពតាម ឬនឹងមិនគោរពតាមនោះទេ។

ដើម្បីតែងតាំងមេធាវីណាម្នាក់ផ្សេងទៀតដោយសារតែការសម្រេចចិត្តរបស់ នួន ជា មិនស្វែងរកជំនួយក្នុងអំឡុងពេលសវនាការបណ្តឹងសាទុក្ខចុងក្រោយពីក្រុមមេធាវីការពារក្តីដ៏ធំនិងដែលទទួលបានមូលនិធិ យ៉ាងល្អនោះទេ។

៣៤. ទោះជាយ៉ាងណា ប្រសិនបើ នួន ជា តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងតាមរយៈប្រព័ន្ធសោទស្សន៍ស្របតាមវិធាន ៨២(៥) នៃវិធានផ្ទៃក្នុងនោះ អជតក អាចសុំធានាឲ្យបានថាគាត់អាចទំនាក់ទំនងជាមួយនឹងមេធាវីរបស់គាត់នៅក្នុងបន្ទប់សវនាការ (ធនធានដែលមានរួចជាស្រេច និងត្រូវបានប្រើប្រាស់ជាប្រចាំនៅពេលដែល នួន ជា តាមដានកិច្ចដំណើរការនិតិវិធីពីបន្ទប់ឃុំខ្លួន) ឬ ប្រសិនបើមេធាវីមានវត្តមាននៅក្នុងតុលាការនោះទេ មន្ត្រីតុលាការម្នាក់មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួន និងអាចទំនាក់ទំនងជាមួយនឹង អជតក បាន ប្រសិនបើ នួន ជា មានបំណងប្រាប់តុលាការលើបញ្ហាណាមួយ ដែលកើតមានឡើងក្នុងអំឡុងពេលសវនាការនានានៃបណ្តឹងសាទុក្ខនេះ ឬពិចារណាការសម្រេចចិត្តរបស់គាត់ឡើងវិញចំពោះការណែនាំមេធាវីរបស់គាត់ឲ្យពហិការកិច្ចដំណើរការនីតិវិធីនោះ។

៣៥. វិធាន ៨១(៧) នៃវិធានផ្ទៃក្នុង ក៏មិនអាចអនុវត្តបាននៅទីនេះដែរ។ ការណ៍នេះបញ្ជាក់ថា "នៅពេលមេធាវីរបស់ជនជាប់ចោទ មិនមានវត្តមានក្នុងអំឡុងពេលសវនាការដោយគ្មានការបញ្ជាក់អំពីមូលហេតុ អង្គជំនុំជម្រះសាលាដំបូងអាចពន្យារពេលសវនាការ ឬបើសិនជាជនជាប់ចោទ ស្នើសុំជំនួយមេធាវី អាចស្នើសុំឲ្យអង្គភាពគាំទ្រការការពារក្តី ចាត់តាំងជាបណ្តោះអាសន្នជូនជនជាប់ចោទនោះនូវមេធាវី"។ វាបង្ហាញថាបទប្បញ្ញត្តិនេះមានគោលបំណងគ្របដណ្តប់លើស្ថានភាពនានាដែលអវត្តមានរបស់មេធាវីមិនពាក់ព័ន្ធនឹងអំពើនានារបស់ជនជាប់ចោទ៖ ដូច្នេះ ការយោងទៅលើលទ្ធភាព នៃការតែងតាំងមេធាវីតាមសំណើរបស់ជនជាប់ចោទនៅពេលដែលមិនមានការបញ្ជាក់អំពីការអវត្តមាននោះ។ នៅទីនេះ នួន ជា សហមេធាវីជាតិ និងសហមេធាវីអន្តរជាតិដែលត្រូវបានចាត់តាំងឲ្យគាត់។ គាត់បានណែនាំពួកគេមិនឲ្យចូលរួម។ សេណារីយោដែលថាវិធាន ៨១(៧) ត្រូវបានតាក់តែងឡើងដើម្បីដោះស្រាយនៅពេលដែលជនជាប់ចោទនៅក្នុងបន្ទប់សវនាការមិនមានលទ្ធភាពទទួលបានជំនួយពីមេធាវី ប្រឆាំងទៅនិងឆន្ទៈរបស់គាត់មិនមាននៅទីនេះនោះទេ។

៣៦. សហព្រះរាជអាជ្ញាកត់សម្គាល់ថា ការយល់ឃើញរបស់អង្គជំនុំជម្រះដែលថា "ក្របខ័ណ្ឌផ្នែកច្បាប់ដែលអនុវត្តចំពោះកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក បញ្ជាក់ថា នៅពេលបង្ហាញ

ខ្លួននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ជនជាប់ចោទនៅក្នុងករណីបទឧក្រិដ្ឋ ត្រូវតែទទួលបានជំនួយពីមេធាវី និងថាមេធាវីការពារក្ដីជនជាប់ចោទ ត្រូវតែការពារនៅក្នុងបន្ទប់សវនាការពេញអំឡុងពេលនៃសវនាការបណ្ដឹងសាទុក្ខ ដោយឯករាជ្យ បើទោះបីជាអាចផ្ទុយពីបំណងប្រាថ្នារបស់ជនជាប់ចោទក៏ដោយ"[36]

៣៧. ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាកត់សម្គាល់ថា មាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលបានបញ្ជាក់ថាករណីបទឧក្រិដ្ឋ "ជំនួយ" ពីមេធាវីត្រូវតែមានជាដាច់ខាតនោះ - មិនបានបញ្ជាក់ថា "វត្តមាន" របស់មេធាវីនៅពេលសវនាការឬ ការចូលរួមរបស់ពួកគាត់នៅក្នុងអំណះអំណាងបណ្ដឹងសាទុក្ខផ្ទាល់មាត់ ត្រូវតែមានជាដាច់ខាត នោះទេ។ នៅក្នុង ព្រឹត្តិការណ៍ណាក៏ដោយ សហមេធាវីជាតិដែលបានចាត់តាំងសម្រាប់ នួន ជា បានអះអាងបញ្ជាក់ពីចេតនារបស់ខ្លួនថានឹងមកអង្គុយនៅក្នុងសាលសវនាការ នៅក្នុងអំឡុងពេលនៃសវនាការលើកក្រោយៗទៀតនៃបណ្ដឹងសាទុក្ខនេះ[37]។

៣៨. កិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខដោយមិនមានមេធាវីប្រចាំការ គឺមិនបំពានលើមាត្រា ៣០១ នោះទេ ដោយហេតុថា នួន ជា នៅបន្តធ្វើការផ្ដល់ជំនួយពីមេធាវី តាមការជ្រើសរើសរបស់គាត់ និងរបស់ក្រុមការពារក្ដីដ៏ធំមួយរបស់មេធាវី និងអ្នកជំនួយការផ្សេងៗទៀត។ គាត់បានធ្វើការប្រឹក្សាជាមួយពួកនោះ ហើយច្បាស់ណាស់ថាពួកគាត់បានធ្វើការជាមួយគ្នា នៅក្នុងការអនុវត្តយុត្តិសាស្ត្ររបស់គាត់នៅក្នុងសវនាការលើបណ្ដឹងសាទុក្ខនេះ។ នួន ជា ធ្វើបានយ៉ាងច្បាស់លាស់ថាកាត់បានពេញចិត្តទៅនឹងជំនួយច្បាប់នៅក្នុងក្រុមរបស់គាត់ ប៉ុន្តែ បើអង្គជំនុំជម្រះមានចម្ងល់ណាមួយអំពីបញ្ហានោះ រឿងនេះអាចត្រូវបានបញ្ជាក់ឲ្យច្បាស់លាស់បានជាមួយនឹង នួន ជា។

## អជតក ត្រូវតែធានាថាកិច្ចដំណើរការនីតិវិធីមិនត្រូវបានរារាំង

៣៩. អង្គជំនុំជម្រះក៏ត្រូវតែពិចារណាផងដែរអំពីផលប្រយោជន៍ដ៏លើសលុបក្នុងការធានាថា ការគ្រប់គ្រងលើកិច្ចការរដ្ឋបាលតុលាការនៅក្នុងករណីនេះ ត្រូវមានលក្ខណៈមួយដ៏ឆាប់រហ័សយ៉ាងសមហេតុសមផល ដែលធនធានដ៏មានកម្រិតរបស់តុលាការត្រូវបានប្រើប្រាស់យ៉ាងសមស្រប ហើយភាគីនានាមិនត្រូវបានផ្ដល់រង្វាន់ចំពោះមធ្យោបាយផ្សេងៗ ដែលមានអានុភាពបណ្ដាលឲ្យ

---

36 **F30/15** ការអនុវត្តន៍តាមសេចក្ដីណែនាំ អជតក។

37 **F30/13**, ការឆ្លើយតបរបស់មេធាវីជាតិ លោក សុន អរុណ ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលអំពីហេតុការណ៍ដែលបានកើតឡើង នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥, ១៨ វិច្ឆិកា ២០១៥។

មានការពន្យារពេលជ្រុលហួសហេតុដល់កិច្ចដំណើរការនីតិវិធី និងធ្វើឱ្យការគ្រប់គ្រងលើកិច្ចការរដ្ឋបាលតុលាការមិនបានសម្រេច[38]។

៤០. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR នៅក្នុងករណីរឿងក្តីរបស់ *Barayagwiza* បានបញ្ជាក់ពីទស្សនៈរបស់ខ្លួនថា ជនជាប់ចោទណាម្នាក់ដែលបានជ្រើសរើសធ្វើពហិការលើសវនាការរបស់គាត់ និងបានណែនាំដល់មេធាវីរបស់ខ្លួនមិនឱ្យធ្វើការការពារខ្លួន ជនជាប់ចោទរូបនោះត្រូវបានគេមើលឃើញថាមានការប៉ុនប៉ងរាំងខ្ទប់ដល់កិច្ចដំណើរការនីតិវិធីរបស់តុលាការ៖

> នៅក្នុងករណីរឿងក្តីមួយនេះ លោក Barayagwiza គឺជាក់ស្តែងបានធ្វើពហិការដល់តុលាការរបស់អង្គការសហប្រជាជាតិ។ គាត់បានជ្រើសរើស ទាំងអវត្តមាននៅក្នុងសវនាការ និងទាំងមិនផ្តល់សេចក្តីណែនាំណាមួយទាក់ទងទៅនឹងវិធីដែលអ្នកតំណាងខាងផ្នែកច្បាប់របស់ខ្លួន ត្រូវធ្វើនៅក្នុងសវនាការ ឬទាក់ទងទៅនឹងភាពជាក់លាក់នានានៃយុត្តិសាស្ត្ររបស់ខ្លួន។ *នៅក្នុងស្ថានភាពបែបដូច្នេះ មេធាវីរបស់គាត់គឺគ្រាន់តែមិនអាចគោរពតាម "សេចក្តីណែនាំ" របស់គាត់ដែលមិនឱ្យការពាររូបគាត់ ប៉ុណ្ណោះ។ តាមការយល់ឃើញរបស់តុលាការ សេចក្តីណែនាំបែបដូច្នេះត្រូវបានគេមើលឃើញថាជាការប៉ុនប៉ងមួយក្នុងការរាំងខ្ទប់ដល់កិច្ចដំណើរការនីតិវិធីរបស់តុលាការ។* នៅក្នុងស្ថានភាពបែបដូច្នេះ វាមិនអាចត្រូវបានអះអាងយ៉ាងសមហេតុសមផលនោះទេ ថាមេធាវីត្រូវស្ថិតនៅក្រោមកាតព្វកិច្ចធ្វើតាមសេចក្តីណែនាំទាំងនោះ ហើយថាការដែលមិនធ្វើដូច្នោះនឹងបង្កើតឱ្យមានជាទឡ្ហីករណ៍សម្រាប់ការដកថយ[39]។

៤១. វាមានលក្ខណៈសំខាន់យ៉ាងជាក់ស្តែងសម្រាប់ អជតក ក្នុងការធានាថា ការប៉ុនប៉ងនានាដើម្បីរាំងខ្ទប់ដល់កិច្ចដំណើរការនីតិវិធីរបស់តុលាការ ទោះជាពហិការក្តី ជាការណែនាំដល់មេធាវី មិនឱ្យបង្ហាញខ្លួនក្តី ឬជាការប៉ុនប៉ងដើម្បីបង្ខំឱ្យតុលាការធ្លាក់ចូលទៅក្នុងការពន្យារពេលដ៏ យូរលង់នៅដំណាក់ការចុងក្រោយនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្តី គឺមិនបានទទួល ជោគជ័យ

---

[38] *សូមអាន, ឧទា., រដ្ឋអាជ្ញា ទល់នឹង* Delalić *និងក្រុមគ*, សំណុំរឿង IT-96-21-T, សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទឈ្មោះ Mucić ស្នើសុំឱ្យតែងតាំងមេធាវីថ្មី, ២៤ មិថុនា ១៩៩៦។ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យមានការដកខ្លួនមេធាវីចេញ ប៉ុន្តែបាននិយាយថា ផលប្រយោជន៍ដ៏លើសលុបក្នុងការគ្រប់គ្រងលើកិច្ចការរដ្ឋបាលតុលាការ មានន័យថា ជន ជាប់ចោទមិនត្រូវបានអនុញ្ញាតឱ្យស្វែងរកការដកខ្លួនរបស់មេធាវីរបស់ខ្លួនដែលបានចាត់តាំង ដោយពុំបង្កើតបានទូវមូលហេតុដ៏ សមស្របនោះទេ។ អង្គជំនុំជម្រះក៏បានពិចារណាផងដែរថា តើមានបំណងចង់ធ្វើឱ្យខូចដល់យុត្តិធម៌ បែបដូចជាតាមរយៈការ បណ្តាលឱ្យមានការពន្យារពេលបន្ថែមនេះ ដែរឬទេ។

[39] *រដ្ឋអាជ្ញា ទល់នឹង Barayagwiza*, សំណុំរឿង ICTR-97-19-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំដកខ្លួន ចេញ, ២ វិច្ឆិកា ២០០០, កថាខណ្ឌ២៤ (សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត*)។

នោះទេ។ តុលាការ SCSL ធ្លាប់បានសង្កេតឃើញថា ច្បាប់ព្រហ្មទណ្ឌមិនអនុញ្ញាតឱ្យ មាន អវត្តមានណាមួយ ឬ ជនជាប់ចោទដែលមានលក្ខណៈបន្ទុចបង្អាក់ណាម្នាក់ "ធ្វើការរារាំងដល់ការគ្រប់គ្រងលើកិច្ចការរដ្ឋបាលរបស់តុលាការ ឬធ្វើឱ្យខូចខាតដល់ទីបញ្ចប់ទាំងឡាយនៃយុត្តិធម៌នោះទេ"[40]។

៤២. ច្បាប់របស់ប្រទេសបារាំងបានទទួលស្គាល់ថា អវត្តមានរបស់មេធាវីមិនអាចត្រូវបានអនុញ្ញាតឱ្យធ្វើឱ្យអន្តរាយដល់ការគ្រប់គ្រងលើកិច្ចការរដ្ឋបាលយ៉ាងមានរបៀបរៀបរយរបស់តុលាការ បាននោះទេ និងការចាំបាច់មួយក្នុងការធានាថាជនជាប់ចោទត្រូវបានវិនិច្ឆ័យសេចក្តីនៅក្នុងរយៈពេលមួយដ៏សមហេតុសមផល[41]។ ច្បាប់របស់ប្រទេសបារាំងក៏បានទទួលស្គាល់ផងដែរថា អវត្តមានរបស់ជនជាប់ចោទ និងមេធាវីរបស់គាត់ នៅក្នុងអំឡុងពេល ទាំងស្រុង ឬមួយផ្នែក នៃសវនាការ អវត្តមានខ្លួនឯងនោះ មិនអាចធ្វើឱ្យសវនាការអស់សុពលភាពបានទេ (ល្គឹកណាតែអវត្តមាននោះជាកំហុសរបស់អង្គជំនុំជម្រះ ឬ របស់អយ្យការ) ហើយមិនអាចបង្កើតបានជាឧបសគ្គមួយ

---

40 *រដ្ឋអាជ្ញា ទល់នឹង* Sesay *និងគូកន*, សំណុំរឿង SCSL-04-15-T-285, (អង្គជំនុំជម្រះសាលាដំបូង) ការធ្វើការសម្រេចលើបញ្ហានៃការបដិសេធរបស់ជនជាប់ចោទទីបី, ឈ្មោះ Augustine Gbao, មិនចូលរួមនៅក្នុងតុលាការពិសេសសម្រាប់ប្រទេសស៊ីរ៉ាឡេអូន នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៤ និង ថ្ងៃជាបន្តបន្ទាប់ទៀត, ១២ កក្កដា ២០០៤, កថាខណ្ឌ៨។ ស្រដៀងគ្នានេះដែរ នៅតុលាការកំពូលរបស់សហរដ្ឋអាមេរិក នៅក្នុងករណីរឿងក្តីមួយរវាង *Feretta ទល់នឹង រដ្ឋកាលីហ្វ័រនីយ៉ា*, ចៅក្រម Blackmun បាននិយាយថា៖ "ខ្ញុំមិនអាចយល់ព្រមបានទេថា អ្វីក៏ដោយនៅក្នុងខចែងស្តីពីនីតិវិធីដ៏ត្រឹមត្រូវ ឬនៅក្នុងវិសោធនកម្ម លើកទីប្រាំមួយ ដែលតម្រូវឱ្យរដ្ឋនានាស្ថិតនៅក្រោមកិច្ចការដ៏ឱឡារិកនៃការកាត់សេចក្តីព្រហ្មទណ្ឌមួយឱ្យបានដល់នូវកបិចិត្ត - ទោះជាដោយស្ម័គ្រចិត្តក៏ដោយ - ដែលការគិតនឹកភ្លាមៗរបស់ជនជាប់ចោទនីមួយៗ ប្រាថ្នាប្រើប្រាស់សវនាការរបស់ខ្លួន ធ្វើជា យានសម្រាប់ការពេញចិត្តផ្ទាល់ ជាបុគ្គល ឬ ជានយោបាយ"។ *Feretta ទល់នឹង រដ្ឋកាលីហ្វ័រនីយ៉ា*, ៤២២ ស.រ.អា ៨០៦ (១៩៧៥) ត្រង់ ៨៤៩។

41 *"Si l'article 274 de ce Code, comme l'article 6.3c de la Convention européenne de sauvegarde des droits de l'homme et des libertés fondamentales, reconnaissent à l'accusé le droit de choisir librement son défenseur, la nécessité d'assurer la continuité du cours de la justice et celle de permettre le jugement des accusés dans un délai raisonnable, font obstacle à ce que l'absence du défenseur choisi entraîne nécessairement le renvoi de l'affaire."* *សូមអាន* Cass. Crim., ៥ ធ្នូ ១៩៩០, លេខ ៩០-៨១៧៦១។ នៅក្នុងករណីរឿងក្តីនោះ ដោយហេតុថា មេធាវីនានា ដែលបានជ្រើសរើសដោយជនជាប់ចោទមិនមានវត្តមាន មេធាវីថ្មីមួយរូបត្រូវបានចាត់តាំងដោយតុលាការ ហើយការពន្យារ ពេលមួយត្រូវបានអនុញ្ញាតឱ្យគាត់ដើម្បីត្រៀមរៀបចំកិច្ចការពាររបស់គាត់។ ការណ៍នេះ គឺមានលក្ខណៈផ្សេងគ្នាពីកាលៈទេសៈ បច្ចុប្បន្ន ដែលក្រុមមេធាវីការពារក្តីរបស់ នួន ជា មានវត្តមាននៅក្នុងបរិវេណនៃអង្គជំនុំជម្រះ ហើយស្គាល់យ៉ាងច្បាស់នូវ កំណត់ត្រាដ៏ច្រើននៅអង្គជំនុំជម្រះសាលាដំបូង និងនៅអង្គជំនុំជម្រះតុលាការកំពូល។

ទៅនឹងការបន្តធ្វើសវនាការទៅមុខទៀត ដោយមានគោលបំណងដើម្បីធានាដល់ការកាត់សេចក្តីនៅក្នុងរយៈពេលមួយដ៏សមហេតុសមផល[42]។

៤៣. ជាឧទាហរណ៍ *អង្គជំនុំជម្រះសាលាវិនិច្ឆ័យ* របស់ប្រទេសបារាំង បានលើកឡើងពីស្ថានភាពមួយដែលមេធាវីការពារក្តីពីរនាក់ដែលបានចាត់តាំងឱ្យទៅជនជាប់ចោទ បានសម្រេចចិត្តចាកចេញពីសាលសវនាការ ហើយជនជាប់ចោទក៏ចាកចេញដែរ។ មេធាវីម្នាក់ក្នុងចំណោមមេធាវីពីរនាក់ដែលបានចាត់តាំងនោះ បានបដិសេធបេសកកម្មរបស់គាត់ដោយមានហេតុផលថា ប្រធាននៃអង្គជំនុំជម្រះនោះមិនព្រមទទួលយកទេ។ ទោះបីជាដូច្នេះក៏ដោយ ក៏មេធាវីរូបនោះបានចាកចេញពីសាលសវនាការ។ ក្រោយពីនោះមក ការជំនុំជម្រះក្តីក៏ចាប់ផ្តើមដោយអវត្តមានរបស់ជនជាប់ចោទ (ដែលមិនធ្វើតាមដីកាកោះដែលបានដាក់ឈ្មោះគាត់ជាប់ជាប្រចាំ) និងអវត្តមានរបស់មេធាវីដែលបានចាត់តាំង។ *អង្គជំនុំជម្រះសាលាវិនិច្ឆ័យ* បានសម្រេចគាំទ្រលើសេចក្តីសម្រេចរបស់ប្រធានតុលាការជាន់ទាប ឱ្យបន្តកិច្ចដំណើរការនីតិវិធីតទៅទៀត និងបានសម្រេចថា អវត្តមានរបស់ជនជាប់ចោទ និងអវត្តមានរបស់មេធាវីការពារក្តី នៅក្នុងអំឡុងពេល ទាំងស្រុង ឬមួយផ្នែកនៃសវនាការអាចគ្រាន់តែធ្វើឱ្យសវនាការអស់សុពលភាពកាលណាអវត្តមាននោះបណ្តាលមកពីអង្គជំនុំជម្រះ មកពីប្រធានតុលាការ ឬមកពីអយ្យការតែប៉ុណ្ណោះ។ អវត្តមានដោយស្ម័គ្រចិត្តមិនអាចបញ្ឈប់កិច្ចដំណើរការនីតិវិធីបានទេ ដែលចាំបាច់វាត្រូវតែធ្វើបន្តទៅមុខទៀតក្នុងគោលបំណងដើម្បីធ្វើការកាត់សេចក្តីលើជនជាប់ចោទ នៅក្នុងរយៈពេលមួយដ៏សមហេតុសមផល[43]។

៤៤. ស្ថានការណ៍ដ៏លំបាកដែលនៅក្នុងនោះ អជតក ខ្លួនឯងបានជួបប្រទះក្នុងពេលនេះ គឺបណ្តាលមកពីសេចក្តីសម្រេចរបស់ នួន ជា ទាំងស្រុង ហើយដែលធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់ ជនរងគ្រោះ ប្រជាជនកម្ពុជា និង សហគមន៍អន្តរជាតិ ក្នុងការនាំយកសំណុំរឿង០០២/០១ ឱ្យទៅដល់ទីបញ្ចប់បានយ៉ាងឆាប់រហ័សនោះ។ មិនមានតុលាការណាមួយគួរអនុញ្ញាតឱ្យមានល្បិចកលផ្សេងៗរបស់ភាគីនានាទៅនឹងករណីរឿងក្តីណាមួយ ដែលធ្វើឱ្យបញ្ឈប់ ឬពន្យារដល់កិច្ចដំណើរការនីតិវិធីដោយពុំមានមូលហេតុសមស្របនោះ បានឡើយ។

---

[42] *សូមអាន* Cass. Crim., ២៦ វិច្ឆិកា ២០១៤, លេខ ១៣-៨៤៩១៤ និង Cass. Crim., ១៣ កុម្ភៈ ២០០៨, លេខ ០៧-៨៣១៦៨។ នៅក្នុងករណីទាំងពីរនេះ *អង្គជំនុំជម្រះសាលាវិនិច្ឆ័យ* បាននិយាយថា៖ *"Attendu que l'absence de l'avocat d'un accusé pendant tout ou partie des débats n'entraîne la nullité de la procédure qu'autant qu'elle est le fait de la cour, du président ou du ministère public."* ។

[43] *សូមអាន* Cass. Crim., ២៤ មិថុនា ២០១៥ , លេខ ១៤-៨៤២២១។

## V. សេចក្តីសន្និដ្ឋាន

៤៥. អាស្រ័យដូចមូលហេតុជំរាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពសូមឱ្យអង្គជំនុំជម្រះកុំបន្តចាត់នីតិវិធីតែងតាំងមេធាវីប្រចាំការ និង៖

ក) សួរ នួន ជា ដោយបុគ្គលផ្ទាល់ ដើម្បីកំណត់ថាតើសេចក្តីសម្រេចលះបង់សិទ្ធិ របស់ នួន ជា ក្នុងការបានជំនួយពីមេធាវីជាតិ និងអន្តរជាតិ ក្នុងពេលសវនាការលើបណ្តឹងសាទុក្ខនេះ គឺជាសេចក្តីសម្រេចមួយដែលធ្វើឡើងដោយ នួន ជា ខ្លួនគាត់ផ្ទាល់ ឬមួយយ៉ាងណា។

ខ) បញ្ជាក់ថាតើ នួន ជា យល់ថាការលះបង់សិទ្ធិរបស់គាត់ មានន័យថា ពុំមានមេធាវីណាម្នាក់ ត្រូវធ្វើការបង្ហាញអំណះអំណាងបន្ថែមទៅលើអំណះអំណាងជាលាយលក្ខណ៍អក្សរ ត្រូវធ្វើការជំទាស់ ឬត្រូវឆ្លើយតបទៅនឹងអំណះអំណាងរបស់ភាគីនានា ឬមួយក៏ត្រូវឆ្លើយទៅនឹងសំនួរណាមួយរបស់ចៅក្រម ដែរឬទេនិងយល់ថាគាត់នៅមានសេរីភាពក្នុងការណែនាំឱ្យមេធាវីរបស់គាត់ការពារគាត់ឡើងវិញនៅពេលណាមួយ តែថាកិច្ចដំណើរការនីតិវិធីដែលបានស្តាប់ក្នុងរយៈពេលអវត្តមានរបស់មេធាវីគាត់ ឬមួយដោយពុំមានការចូលរួមយ៉ាងសកម្មរបស់ពួកគាត់ នឹងមិនត្រូវបានយកមកធ្វើឡើងវិញទេ។

គ) ដោយមិនមានវត្តមាននៅក្នុងសាលសវនាការ បើសិនជា នួន ជា តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ តាមរយៈការភ្ជាប់ប្រព័ន្ធសោតទស្សន៍ អនុលោមតាមវិធាន៨១(៥) ហើយមិនមានមេធាវីរបស់គាត់ណាម្នាក់មានវត្តមាននៅក្នុងសាលសវនាការដែលរូបគាត់អាចទំនាក់ទំនងបាននោះ ត្រូវធានាថាមានវត្តមានរបស់មន្ត្រីតុលាការណាម្នាក់នៅក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ និងមានលទ្ធភាពធ្វើការប្រាស្រ័យទាក់ទងគ្នាជាមួយនឹង អជតក បើសិនជា នួន ជា មានបំណងចង់ជម្រាបតុលាការ អំពីបញ្ហាណាមួយដែលបានកើតឡើងក្នុងពេលសវនាការលើបណ្តឹងសាទុក្ខនេះ។

ឃ) សុំឱ្យ នួន ជា ធ្វើការបញ្ជាក់ដោយបុគ្គលផ្ទាល់ជារៀងរាល់ថ្ងៃនៃសវនាការលើបណ្តឹងសាទុក្ខនេះ ថាតើគាត់មានបំណងនឹងបន្តលះបង់សិទ្ធិរបស់គាត់ក្នុងការចូលរួមតទៅមុខទៀត នៅក្នុងសវនាការលើបណ្តឹងសាទុក្ខនេះ ដែរឬទេ។ និង

ង) បន្តធ្វើសវនាការលើបណ្តឹងសាទុក្ខនេះឡើងវិញ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
| --- | --- | --- | --- |
| ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ | **លោក សេង ប៊ុនឃាង** សហព្រះរាជអាជ្ញារង្តីទី | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN** សហព្រះរាជអាជ្ញា | | [signature] |